# COMBIEN SONT LES KHMER KROM ?

ស្រង់ចេញពី : សិក្សាខ្មែរ Etudes Khmères
Revue du Centre de Documentation et de Recherche sur la Civilisation Khmère ( CEDOREK )

ដោយ Jacques NEPOTE ( C.N.R.S. )

# តើខ្មែរក្រោម មានប៉ុន្មាន?

ប្រែសំរួលដោយ អេខ~សេរីបុត្រ

ការផ្សាយរបស់សារពត៌មាន«អង្គរបូរី»
រក្សាសិទ្ធិគ្រប់យ៉ាង

(គ.ស.២០០៤ - ព.ស.២៥៤៨)

**និក្ខេបបទរបស់យួន** ៖ ចំពោះមតិ-សតិសម្បជញ្ញៈរបស់ជនជាតិយួនជាទូទៅ បញ្ហាភូមិភាគត្រង់មាត់ទន្លេមេគង្គ ( la région des bouches du Mékong ) នាពេលបច្ចុប្បន្ននេះ វាបានក្លាយទៅជាដែនដីរបស់យួនសុទ្ធសាធទៅហើយ ។ វាពុំមានចោទជាបញ្ហាអ្វីធំដុំទេ ហើយកន្លងរួចមកក៏ពុំដែលបានចោទជាបញ្ហាអ្វីដែរ ។ តាមធាតុពិត មួយភាគធំនៃដែនដីទន្លេមេគង្គ ដែលលយចូលទៅក្នុងសមុទ្រ ( delta ) នោះ បានធ្លាក់ទៅក្នុងកណ្ដាប់ដៃយួនអស់ទៅហើយ ទោះបីតាមផ្លូវច្បាប់ ក៏ដូចតាមផ្លូវកាន់កាប់ក៏ដោយ ។ បុព្វហេតុនេះដែលបណ្ដាលមកពីជំរៀតជំរែករបស់ប្រជាជនឈ្លានពានចូលមកបន្តិចម្ដងៗទៅមុខជានិច្ច ដោយឥតប្រែត្រឡប់ថយក្រោយសោះឡើយ - ដោយការរៀបចំភូមិស្រុក - រៀបចំដីធ្លី និងដោយចំណាត់ចំណែងផ្នែករដ្ឋបាល ដែលគេបានរៀបចាត់ចែងឡើង យ៉ាងហោចណាស់តាំងពីដើមសតវត្សទី១៧មកម្ល៉េះ ។ ការធ្វើយូនូបនិយកម្មនៃទឹកដីត្រង់នេះ បានចាប់ផ្ដើមធ្វើដំណាលគ្នានិងដោយស្របច្បាប់ នៅពេលដែលទឹកដីត្រង់កន្លែងនោះនៅមិនសូវទាន់មានប្រជាពលរដ្ឋរស់នៅ ហើយដែលឃ្លាតចាកពីកិច្ចត្រួតត្រាផ្នែកនយោបាយ ។ តើគេអាចពិចារណាផ្សេងយ៉ាងណាទៅទៀតបាន បើទឹកដីត្រង់តំបន់នេះភាគធំសុទ្ធជាវាលភក់ល្បប់ រួចជាកន្លែងដែលនាំឲ្យអន្តរាយដល់សុខភាព ( insalubre ) និងជាទីកើតប្រទូស្តរាយច្បាំងគ្នា ជាអមិត្តភាព ( hostile ) ទៅទៀត ។ ក្រៅតែពីកុលសម្ពន្ធខ្លះៗ ដូចជាពួកស្បៀងនិងក្រុមផ្សេងៗខ្លះទៀត រស់នៅដោយប្រកបរបររកចិញ្ចឹមជីវិតកំប៉ិកកំប៉ុក នៅតាមជើងវាលខ្ពង់រាបផ្នែកខាងក្នុង គេប្រទះឃើញពួកម៉ាឡេមួយចំនួនតូចប្រកបរបរជាអ្នកនេសាទ សង់ផ្ទះសំប៉ែងនៅតាមមាត់ទឹក រួចក្រោយមកទៀត មានសហគមខ្មែរមិនជាច្រើនប៉ុន្មានណាស់ណាពេកទេ ( សហគមនេះគឺជានិគមជនដែរ បានមករស់នៅត្រង់តំបន់ដីដុះថ្មីលយចេញពីជ្រោយញោចនៃមាត់ទន្លេ ) ហើយតាំងពីលំនៅនៅមិនឆ្ងាយប៉ុន្មានពីមាត់ទន្លេបឹងបួរ ដែលជាតំបន់មួយប្រកបទៅដោយដីមានជីវជាតិច្រើន សំរាប់របរកសិកម្មអាចចិញ្ចឹមជីវិតដល់ប្រជាពលរដ្ឋបានយ៉ាងច្រើន...។ មានការជីកប្រឡាយបង្ហូរទឹក ប្រព័ន្ធទំនប់ខ្វាត់ខ្វែងដែលបានចាត់ចែងឡើងដោយរាជវង្ស « ង្វៀង » ចុះមកពីក្រុងវ៉េ ។ កិច្ចការទាំងអស់នោះហើយ ដែលផ្ដល់កំណើតឲ្យឈ្មោះដល់ដែនដីកូសាំងស៊ីន ដោយមានការរៀបចំផ្សព្វផ្សាយផ្នែករដ្ឋបាលនៅតាមភូមិករនានា- ផ្សព្វផ្សាយនូវអារ្យធម៌ក្នុងការសរសេរ និងមនោគមវិជ្ជាសព្វបែបយ៉ាង ឲ្យក្លាយទៅជារដ្ឋទំនើបដូចគេ ដោយភ្ជាប់សំបុត្រស្នាមផ្នែកវប្បធម៌បែបបទជាយួនទៅក្នុងប្រទេស ។ ចុងបញ្ចប់ ដោយការតែងតាំងប្រមូលផ្ដុំប្រជាករស្របទៅតាមសហគមសំរាប់ជាប-

ណ្តាក់គ្នាជាជំនួស ពោលគឺសហាគមចិននៃពូជពង្សវង្សត្រកូល « ម៉ីង » ដែលជនជាតិខ្មែរក្រោមបានស្ម័គ្រចិត្តរៀបចំបង្កបង្កើតជាសាច់ញាតិ-គ្រួសារដោយសុទ្ធចិត្ត ហើយដែលការរលាយពូជសាសន៍ទាំងពីរនេះហើយ ដែលគេអាចចាត់ទុកជាជនជាតិ ដែលមានលក្ខណៈជា « ជនជាតិភាគតិចរបស់ជាតិ » ដែលគេបានទទួលស្គាល់ជាជនជាតិសាសន៍ព័ន្ធ ( ethnics ) មិនមែនជាជនជាតិវៀតណាម ដែលយួនឲ្យឈ្មោះថា « ជាជនជាតិយួនកំណើតជាខ្មែរ nguoi viet goc mien » ដែលតាមពិតជនទាំងនោះជាខ្មែរពិតប្រាកដ ។

និក្ខេបបទរបស់ខ្មែរ ៖ ទោះបីជាមិនបានបដិសេធឲ្យបានពិតប្រាកដពីជំរៅនៃការឈ្លានពានរបស់យួនក៏ដោយ ក៏និក្ខេបបទរបស់ខ្មែរមានភាពផ្ទុយគ្នាស្រឡះពីនិក្ខេបបទរបស់យួន ដោយផ្អែកទៅលើចំណុចសំខាន់ៗដូចតទៅនេះ ៖

១- ការមកតាំងទីលំនៅនៅលើទឹកដីមាត់ទន្លេមេគង្គ ( les bouches du Mékong ) នៃជនជាតិបរទេសទាំងនោះ មានជ្វា-ចិន-យួន-ចាម ឬក៏សាសន៍ដទៃទៀត បានប្រព្រឹត្តទៅជាបឋម ដោយទទួលស្គាល់ជាមូលដ្ឋាន នូវច្បាប់ដ៏ឧត្តមនៃរាជបល្ល័ង្ករបស់ខ្មែរ ដោយរួមទាំងការទទួលស្គាល់ពីព្រះចៅក្រុងវេទៀតផង ។ យើងគួរបញ្ជាក់ថែមទៀតថា នៅលើផែនការសីលធម៌និងផ្លូវច្បាប់នៃកិច្ចការរដ្ឋបាល គឺរបស់យួនសុទ្ធសាធឥតប្រកែកបានសោះឡើយ ។ និយាយដោយចំ ( ដោយឥតបញ្ឆិតបញ្ឆៀង ) ការតែងតាំងរដ្ឋបាលយួនបានប្រព្រឹត្តទៅ នាពេលក្រោយដ៏យូរអង្វែងមក ទោះបីឥតមានការយល់ព្រម ឬមានការជំទាស់អ្វីក្នុងផ្នែកការទូតទាំងស្រុង និងជាយថាហេតុក៏ដោយ ។ ទោះបីជាមិនទាន់មានអ្នកណាម្នាក់ ចាត់ទុកថាកិច្ចការធ្វើបែបនេះជាការឥតប្រយោជន៍ក៏ដោយ ក៏យ៉ាងហោចណាស់តាមផ្លូវច្បាប់ពិតប្រាកដ បញ្ហានៅមិនទាន់ចប់នៅឡើយ ។

២- មនោសញ្ចេតនានៃភាពមិនស្របច្បាប់នេះ (ce sentiment d'illégitimité ) បានត្រូវទទួលសារភាពដោយផ្ទាល់ពីអាជ្ញាធរយួនខ្លួនឯងតែម្តង ព្រោះថាទឹកដីត្រង់នេះនៅតែមានដំណើរវិលវល់ឥតឈប់ឈរ ( cycliquement ) មិនទាន់បានប្រគល់ទៅរាជបល្ល័ង្កខ្មែរនៅឡើយ នូវអាណាខេត្តទាំងឡាយណាដែលយួនបានប្រវ័ញ្ចយកដោយប្រើកម្លាំងទ័ព ហើយដែលយួនត្រូវតែទទួលស្គាល់ថា ជារាជទ្រព្យនៃរាជវង្សខ្មែរឬក៏អត់ទេ...។ម៉្យាងវិញទៀត គោងយួនបើកឲ្យមានសិទ្ធិស្មើគ្នាចំពោះប្រជាពលរដ្ឋដែលស្ថិតនៅលើដែនដីកូសាំងស៊ីន ព្រោះថាជាការផ្ទុយទៅវិញ រហូតមកដល់ពេលសព្វថ្ងៃនេះ ខ្មែរក្រោមនៅតែស្ថិតនៅក្នុងជួរទី១ក្នុងវិស័យវប្បធម៌និងវិស័យនយោបាយរបស់រដ្ឋកម្ពុជាដដែល ។

៣- ការធ្វើអាណានិគមលើទឹកដីជ្រោយពាមទន្លេ ( delta ) និងការធ្វើអាជីវ-កម្មបែបបទក្បួនខ្នាត ទោះបីមានការធ្វើអន្តោប្រវេសន៍យ៉ាងសន្ធឹកសន្ធាប់នៃនិគមជនយួនក៏ដោយ ក៏កិច្ចការទាំងនោះមិនមែនបញ្ជាក់ ឬបណ្តាលឲ្យសន្មត់យ៉ាងពិតប្រាកដថា ទឹកដីត្រង់នេះជារបស់ « យួន vietnamisé » នោះឡើយ ព្រោះថាអ្វីដែលជាគោលសំខាន់នៅត្រង់ការផ្លាស់ប្តូរដីសំរាប់ធ្វើកសិកម្ម ( terroir ) នៅទីនោះទើបតែនឹងប្រែប្រួលនៅពេលថ្មីៗកន្លងមកនេះហើយសោះដែលចាត់ចែងធ្វើឡើងដោយមន្ទីរបារាំងសែសនៅឥណ្ឌូចិន (Services françaises de l'Indochine) ។

វត្តមានរបស់ជនជាតិយួន វាគ្រាន់តែជាពលករ ជាពលៈជីវីស៊ីឈ្នួលជួលព័ទ្ធក្នុងឋានៈជាជនអន្តោប្រវេសន៍- ជាវណ្ណៈពលៈជីវី ឬជាវណ្ណៈអធន ដែលគ្មានឫសគល់អ្វីទាំងអស់ គ្រាន់តែធ្វើការបំរើក្នុងកិច្ចការស្រែភ្លឺធំដុំ និងជារបរកសិកម្មតាមបែបបទមូលធននិយមតែប៉ុណ្ណោះ ។ អាស្រ័យហេតុនោះហើយ ទើបនៅលើដែនដីកូសាំងស៊ីនមួយភាគធំ បានត្រូវក្រសួងផែនទីខ្មែររក្សាទុក ហើយមិនតែប៉ុណ្ណោះលើទឹកដីនេះទាំងមូលបានរក្សាទុកនៅដដែល នូវទស្សនិយភាព ទេសភាព មានលក្ខណៈជាខ្មែរសុទ្ធសាធ ។ ព្រឹត្តិហេតុទាំងនោះហើយ ដែលបានផ្តល់ជាលក្ខណៈច្បាស់លាស់ពិតប្រាកដជារបស់ខ្មែរ ដែលជាការផ្ទុយស្រឡះពីលក្ខណៈទឹកដីសំរាប់ធ្វើកសិកម្មដែលជារបស់ផងយួន...។

៤- ហើយដែលនៅទីបំផុត ដែលគេអាចចាត់ទុកបានថាជាទឹកដីរបស់ខ្មែរយ៉ាងពិតប្រាកដ ព្រោះមានវត្តមាននៃជនជាតិខ្មែរនៅជាប់ជានិច្ច ជារៀងរហូតលើទឹកដីកម្ពុជាក្រោម Kambujà Krom ou le Cambodge d'aval ។ កេរ្តិ៍មរតកដូនតារបស់ពួកគេរាប់តំណាមនុស្សមកហើយ ៗមាតុភូមិកំណើតផ្សព្វផ្សាយនូវអរិយធម៌ដ៏រុងរឿងរបស់ខ្មែរទៀតផង ។ ទោះបីមានឧបសគ្គជាច្រើនដែលបង្កបង្កើតឡើងដោយរដ្ឋបាលយួនយ៉ាងណាក៏ដោយ ក៏គេអាចប្រមាណឃើញមានជនជាតិខ្មែរក្រោមជាច្រើនលាននាក់ឯណោះ ហើយជាពិសេសនៅតាមខេត្តខ័ណ្ឌនានា តាមភូមិភាគមាត់ទន្លេបាសាក់ខ្លះៗ(dans certaines provinces du Tranbassac) ជនជាតិខ្មែរក្រោមនៅតែមានចំនួនភាគច្រើន ( la majorité ) ជានិច្ចក្នុងចំណោមជាតិសាសន៍ដទៃទៀត ។

<u>វិលទៅសំអាងលើស្ថិតិជាកណ្តាល-ជាអព្យាក្រឹត្យ ( le recours à la neutralité statistique )</u> ៖

នៅក្នុងក្របខ័ណ្ឌនៃអត្ថបទវែកញែកនេះ អ្នកនិពន្ធពុំមានបំណងលើកយកមកពិភាក្សា ថានិក្ខេបបទណាខុសណាមួយត្រូវនោះទេ ពោលគឺឥតលំអៀងទៅខា

ងណាៗឡើយ តែចង់រកឲ្យឃើញនូវភាពសមហេតុផល ពីការវិវត្តន៍ប្រែប្រួលនៃចំនួនប្រជាជននេះតែប៉ុណ្ណោះ ។ *តាមធាតុពិត បញ្ហាខ្មែរក្រោមនេះតម្រូវឲ្យយើងកាន់តែចង់ដឹងកាន់តែខ្លាំងឡើង ។ ព្រោះថារបៀបដែលគេហៅថា « ប្រជាជនយួនមានកំណើតខ្មែរនោះ* nguoi viet goi mien *» គឺជារឿងប្រឌិតសុទ្ធសាធ ដើម្បីបិទបាំងនូវការពិត អ្វីមួយប៉ុណ្ណោះ ។ ទោះបីសហគមខ្មែរក្រោមមានទម្រង់លក្ខណៈខុសគ្នាខ្លះៗហើយ ទោះបីអ្នកធ្វើនិក្ខេបបទខ្លះបំរុងខ្លួនដើម្បីបំរើនយោបាយយួនក៏ដោយ ក៏ខ្មែរក្រោមនៅ តែជាសហគមស្វយ័តមួយ ប្រកាន់ខ្ជាប់ខ្ជួននូវភាសាដើមកំណើតរបស់ខ្លួន, ប្រតិបត្តិ យ៉ាងតឹងរឹងនូវប្រពៃណីខ្លួន, នូវសាសនារបស់ផងខ្លួន, ស្គាល់យ៉ាងច្បាស់លាស់នូវប្រវត្តិសាស្ត្ររបស់ខ្លួន ដោយសរុបទៅ គឺខុសពីជនជាតិសាសន៍យួនសុទ្ធសាធ ។ ដូច្នេះចំណុចចាប់ផ្តើមរបស់យើងស្ថិតនៅត្រង់ចង់ដឹងថា តើដោយពិតប្រាកដ ខ្មែរក្រោមមានទាំងអស់ប៉ុន្មាន ?*

តាមការពិត គ្មានអ្វីដែលងាយស្រួលនោះទេ ព្រោះថាចាប់តាំងពីពាក់កណ្តាលសតវត្សទី១៩មកម្ល៉េះ គេពុំដែលបានធ្វើការជំរឿនប្រជាពលរដ្ឋខ្មែរក្រោមម្តងណាទេ ។ អ្នកធ្វើការជំរឿនប្រជាជននោះទៀតសោត ច្រើនជាវរជនផង ជាវិជ្ជាស្ថានដ៏ល្បីល្បាញផង ក្នុងនោះមានអភិបាលក្រសួងស្ថិតិនេះឯងតែម្តង ។ល។ ក៏ប៉ុន្តែបើសិនជាគេសង្កេតមើលដោយហ្មត់ចត់ទៅ គេសង្កេតឃើញថា ៖ លទ្ធផលដែលចេញមកពីការធ្វើជំរឿនរបស់មជ្ឈដ្ឋានទាំងនោះ ឥតស៊ីសង្វាក់គ្នាទេ ហើយការដែលមិនស៊ីគ្នា-មិនស្របគ្នានោះហើយ ដែលជាកត្តាធ្វើឲ្យមានការព្រួយបារម្ភជាហេតុនាំឲ្យគេខិតខំប្រឹងប្រែងរិះរកមធ្យោបាយផ្សេងទៀត ដើម្បីបំពេញផ្តល់ជូនពត៌មានទាំងនេះ ដោយប្រើឫសំអាងទៅលើប្រភពផ្សេងៗទៀត គឺយ៉ាងនោះហើយដែលគេយកឧទាហរណ៍ខ្លះៗ មានរយៈពេលប្រហាក់ប្រហែលគ្នាមកប្រែដូចតទៅនេះ ៖

– បើតាមអគ្គនាយកដ្ឋានទូទៅនៅអមខុទ្ទកាល័យរដ្ឋមន្ត្រីទី១នៃសាធារណរដ្ឋវៀតណាម (ខាងត្បូង) ហើយដែលនាយកដ្ឋាននោះមានភារៈត្រួតពិនិត្យលើកិច្ចការ « ជនជាតិវៀតណាមដើមកំណើតខ្មែរ Les Viêtmamiens d'origine Khmère » បានសន្និដ្ឋានថា ៖ ខ្មែរក្រោមមានចំនួនទាំងអស់៦៦១,៥៦១នាក់ក្នុងខែកុម្ភៈឆ្នាំ១៩៧៤ ។

– សៀវភៅខ្មែរឧទ្ទិសចំពោះខ្មែរក្រោមមានចំនួន៨,៩៧៥,០០០នាក់ នៅក្នុងឆ្នាំ១៩៦៤ ។

– លោក Miller វិញបានប៉ាន់ស្មានទៅលើកំណើតប្រជាជនខ្មែរក្រោមថា ៖ « That would place the current (1975) Khmer population of South Viêtnam

at 1,638,946 a figure endorsed by myself and unofficially endorsed by a number of Viêtnamese, Hkmer and U.S. authorithies in South Viletnam who prefer to remain anonymous » ។

– សាស្ត្រាចារ្យមហាវិទ្យាល័យ ( ជនជាតិបារាំង ) ម្នាក់ដ៏ល្បីល្បាញថា មានចំណេះវិជ្ជាទូទៅ និងស្គាល់ច្បាស់ពីបញ្ហាខ្មែរ បានប្រមាណថា ៖ ជនជាតិភាគតិចខ្មែរនៅកម្ពុជាក្រោមមានចំនួនប្រហែល ៨០០,០០០នាក់ នៅរវាងចុងឆ្នាំ១៩៧០ ។

★ នៅចុងបញ្ចប់ ហើយជាពិសេសអ្វីដែលគេអាចជឿជាក់បាន គឺវត្តមានខ្មែរក្រោមរស់នៅលើទឹកដីដូនតារបស់គេជានិច្ច ជាអចិន្ត្រៃយ៍រាប់សតវត្សមកហើយ រស់នៅលើទឹកដីកម្ពុជាក្រោម ( Kambujà Krom, leur Cambodge d'aval ) ដែល គេចាត់ទុកថា ជាមជ្ឈដ្ឋានវប្បធម៌នាសម័យរុងរឿងរបស់កម្ពុជា ។ ទោះបីមានឧបសគ្គ មានការគាបសង្កត់យ៉ាងណាពីរដ្ឋបាលយួនគ្រប់សម័យក៏ដោយ ក៏គេនៅតែមានការប៉ាន់ស្មាន ថាខ្មែរក្រោមមានចំនួនយ៉ាងហោចណាស់ ក៏ច្រើនជាងលានដែរ ហើយនៅក្នុងខេត្តខណ្ឌនានា ត្រង់ភូមិភាគទន្លេបាសាក់ ( provinces du Transbassac ) ហើយមិនតែប៉ុណ្ណោះសោត ប្រជាពលរដ្ឋខ្មែរក្រោមមានចំនួនច្រើនលើសគេផង ក្នុងចំណោមប្រជាជនទាំងឡាយដែលរស់នៅក្នុងតំបន់នេះ ។

កំណត់អ្នកបកប្រែ ៖

★ នៅក្នុងឆ្នាំ១៩៦២ ប្រធានាធិបតីង្វៀង-វ៉ាន់ធីវ ( សព្វថ្ងៃរស់នៅទីក្រុងឡុងដ៍ ) នាពេលសម្ពោធសមិទ្ធិក្នុងខេត្តព្រៃកប្បាស្សី ( កឹងថើ ) បានពោលថា ៖ ប្រជាជនវៀតណាមមានដើមកំណើតជាខ្មែរ មានចំនួនទាំងអស់ ៤,៥០០,០០០នាក់ ។ នៅវៀតណាមតាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ អត្រាកំណើន ( Taux d'accroissement ) ប្រជាជនចុះឡើងពី២.៥% ទៅ ៣% ។ ដោយយកតែត្រឹម២% និងយកតាមសំដីប្រធានាធិបតីយួនខាងត្បូងនេះមកគិត ក្រោយពីបានគន់គូរលេខសព្វគ្រប់ទៅ ខ្ញុំយល់ថា ខ្មែរក្រោមនាពេលបច្ចុប្បន្ននេះមានចំនួនយ៉ាងហោចណាស់ ៨,៧០៩,៦០២នាក់ដែរ។ នេះបើយកត្រឹមអត្រាកំណើនតែ២% (២ភាគរយ) ផង ។ បើគិត៣% (៣ភាគរយ) វិញនោះ ខ្មែរក្រោមមានទាំងអស់មិនតិចពី១០លាននាក់ស្ទើរស្មើនឹងប្រជាពលរដ្ឋ នៅកម្ពុជា ឬមានលើសផង ។

ចំណែកខាងប្រភពអាមេរិកាំងដែលគួរឲ្យជឿជាក់បានវិញ បានពោលខុសគ្នាពីទំព័រ១ទៅទំព័រមួយទៀត ស្តីអំពីប្រជាពលរដ្ឋខ្មែរនៅប្រទេសវៀតណាមខាងត្បូងមាន ៖ « estimated to number between 350,000 and 400,000 » រួចបញ្ជាក់ថា « the Theravada minority, numbering about 2 millions, is made up largely of ethnic Cabodians » ទំព័រ១៦៩ ។

- បើនិយាយដោយសំយោគ យកជាកណ្តាលទៅ, ចំនួនប្រជាពលរដ្ឋខ្មែរនៅកម្ពុជាក្រោម ( ឬខ្មែរក្រោម ) ត្រូវបានគេធ្វើការប៉ាន់ស្មាន ប្រែប្រួលទៅតាមអ្នកនិពន្ធ អ្នកស្រាវជ្រាវ និងទៅតាមប្រភពផ្សេងៗ មានចំនួនកើនពីមួយទៅបួនដងឯ-ណោះ ។

ហេតុនេះ, ចំពោះអ្នកស្រាវជ្រាវដែលខ្វះឯកសារត្រឹមត្រូវជាក់ស្តែងយកជាការបាន នៅចំពោះមុខការប្រមូលផ្តុំ គោលដែលផ្តល់ឲ្យផ្ទុយគ្នាបែបនេះពីស្ថានភាពប្រជាជនខ្មែរក្រោម តើនៅចោទជាបញ្ហាឈ្លោះគ្នាតាមរយៈស្លាបប៉ាកាតទៅទៀត រហូតទល់តែថ្ងៃណាមួយ មានការរៀបចំធ្វើអង្កេតមួយ ក្រោមការត្រួតពិនិត្យជាអន្តរជាតិ ទៅលើចំនួនប្រជាពលរដ្ឋ ( ខ្មែរក្រោម ) ដោយធ្វើឡើងជាក្បួនខ្នាត និងដែលឥតលំអៀងទៅខាងណានោះទៅឬ (??) ។ ពោលគឺត្រង់នេះហើយ ដែលយើងនឹងយកមកជជែកវែកញែកគ្នាក្នុងក្របខ័ណ្ឌនៃអត្ថបទនេះ ជាបីសណ្ឋានដូចតទៅ ៖

១- យើងរៀបចំផ្តើមរិះរកឲ្យឃើញទីពិតប្រាកដ ពីបញ្ហាថាតើបញ្ហានៃជនជាតិភាគតិចខ្មែរក្រោម បានចោទឡើងជាបញ្ហា និងកើនឡើងជាលំដាប់ដល់អ្នកកំណត់ប្រមូលឬសួរចំនួនហេតុភេទ ( le statisticien ) ក្នុងរយៈពេលរវាងពាក់កណ្តាលចុងសតវត្សទី១៩តរៀងមក ។

២- រួចហើយ យើងចាប់ផ្តើមធ្វើការសិក្សាជាបន្តបន្ទាប់ ទៅលើកាលសម័យ ឬរដ្ឋបាយមួយ ដែលយោងទៅតាមទ្រឹស្តីអាចចាត់ទុកថាជា « អព្យាក្រឹត្យ » ដូចជារដ្ឋបាលក្នុងសម័យ « ឥណ្ឌូចិនបារាំងសែស Celle de l'Indochine française » នោះជាដើម... ដែលនៅក្រោមសម័យនោះឯងហើយ ដែលវាសនាសហគមខ្មែរក្រោមមានភ័ព្វបានរស់នៅដោយសុខសន្តិភាព ហើយនិងនៅពាក់កណ្តាលដើមសតវត្សទី២០ ។

៣- នៅចុងបញ្ចប់ យើងនឹងធ្វើការវិនិច្ឆ័យស្ថានការណ៍គំនិតស្តីអំពីស្ថានភាពដែលនៅក្នុងពេលសព្វថ្ងៃ ឬក៏ដូចដែលយើងទើបតែនឹងបានគូសបញ្ជាក់រួចមក ហើយអីចឹង... ប្រភពទាំងឡាយមានការខ្វែងគ្នាកាន់តែខ្លាំងឡើងៗ...

# ការលើកយកមកចោទជាបញ្ហាខ្មែរក្រោម

## រយៈពេលនៃការរលាយបាត់រូប ៖

នាពាក់កណ្តាលដើមសតវត្សទី១៩ ពួកបស្ចឹមប្រទេសបានដឹងឮថា នៅត្រង់តំបន់មាត់ទន្លេមេគង្គ ទោះបីស្ថិតនៅក្រោមអធិរាជាណាចក្រយួនក៏ដោយ ក៏មាន

ប្រជាពលរដ្ឋខ្មែរមួយចំនួនធំបានរស់នៅទីនោះ ។ នៅពេលដំណាលគ្នានោះដែរ ពលរដ្ឋខ្មែរក្រោមទាំងនោះ ផ្អាកឈប់នៅត្រង់នោះ ហើយនាំគ្នាសរសៀខិតចូល



រូបថតព្រះសង្ឃ, ដូនជី, អាចារ្យ និងពុទ្ធបរិស័ទចំណុះជើងវត្ត « ចន្ទរង្សី » ទីក្រុងព្រៃនគរ (ប្រទេសកម្ពុជាក្រោម)ថតទុកជាអនុស្សាវរីយ៍នៅ ខាងមុខព្រះវិហារ !

ទៅខាងក្នុងប្រទេសបន្តិចម្តងៗ កាន់តែចៀសចេញឆ្ងាយពីការប្រែប្រួលទៅរកពិ-ភពទំនើប ដែលបាននាំចូលមកកាន់ឥណ្ឌូចិន តាមរយៈកំពង់ផែរបស់ខ្លួន ព្រោះដោយហេតុថាជនជាតិខ្មែរ មិនមែនស្ថិតនៅក្នុងជំពូកជនជាតិដែលចូលចិត្តរស់នៅតាមឆ្នេរសមុទ្រ, ជាអ្នកជំនួញជួញប្រែ ឬក៏ជាកសិករដែលឃ្លាតពីការអនុវត្តន៍ នៃការប្រតិបត្តិជួញកេងគៃយកចំណេញនោះឡើយ ។ ក្នុងកាលៈទេសៈជុំវិញព្រឹត្តិការណ៍បែបនេះ ពួកគេត្រូវបង្ហាញពីការចាញ់ប្រៀបគេពីរប្រការពោលគឺក្នុងផ្នែកភូមិសាស្ត្រនយោបាយ ( Géo-politique) និងក្នុងផ្នែកសង្គមសាស្ត្រវប្បធម៌ ( Socio-culturel ) ។ ស្ថានភាពនយោបាយសម័យថ្មី ធ្វើឲ្យលេចឡើងឃើញកាន់តែច្បាស់ខ្លាំងឡើងៗ ។ នៅចំពោះមុខការប្រកួតប្រជែងជាអន្តរជាតិ ដែលមានការជឿនលឿនលូតលាស់នៃបច្ចេកទេសទំនើបដែលកំពុងឈានទៅមុខនោះ ប្រទេសទាំងឡាយនៃអាស៊ីចុងបូព៌ាគ្មានការជ្រើសរើសឯណា ក្រៅពីការកសាងខ្លួនឲ្យទៅជាប្រ

ទេសទំនើបដូចគេឯងដែរ... ត្រូវខិតខំរឹតចំណងក្នុងផ្នែករដ្ឋបាល រៀបចំក្បួនច្បាប់បង្កបង្កើតជាថ្នាក់ដឹកនាំឲ្យមានឯកភាព ដោយការបង្រួបបង្រួមគ្នា ។ ជាក់ស្តែងកិច្ចការទាំងឡាយនោះ បានសេចក្តីថាព្រះចៅអធិរាជទាំងអស់នៅក្រុងហ្វេ បានណែនាំនិងពង្រីកឥទ្ធិពលរបស់ខ្លួនក្នុងផ្នែករដ្ឋបាលទៅលើដែនកូសាំងស៊ីនទាំងមូលបន្តិចម្តងៗ ឲ្យកាន់តែមានឯកភាព ហើយកាន់តែយកចិត្តទុកដាក់តាំងពីអ្វីៗបន្តិចបន្តួចឡើងទៅ... ហើយដែលតាមផ្លូវនៃផលវិបាកវិញ ញ៉ាំងឲ្យខ្មែរក្រោមកាន់តែពិបាកនឹងទទួលយកបន្តិចម្តងៗ ។ នៅចំពោះការសាកល្បងរបស់ស្តេចអធិរាជយួនដែលចង់ធ្វើយួនូបនិយកម្ម... ការរួមបញ្ចូលបប្លង់ដី ( សុរិយោដី ), ការដាក់បញ្ចូលក្នុងក្របខណ្ឌ... ខ្មែរក្រោមបាននាំគ្នាកំរើកឡើងតវ៉ាទាមទារ ឬក៏ត្រូវរត់ភៀសខ្លួនចេញពីទីនោះ ទៅនៅទីដទៃទៀត ។ រួមសេចក្តីមក កិច្ចការនោះវាត្រឹមតែជាការធ្វើអត្តឃាតចំពោះផលប្រយោជន៍របស់សហគមខ្មែរក្រោមតែប៉ុណ្ណោះ ។ ចំពោះនិន្នាការចង់បានស្វយ័តភាពនិយមនៃរដ្ឋាភិបាលទូទៅនាប៉ែកខាងត្បូង នៅចំពោះបញ្ហាសាសនាកាតូលិក ។ល។ ព្រះចៅអធិរាជយួនមិនអាចយោគយល់បានឡើយ ដូច្នេះបញ្ហាខ្មែរក្រោមឥតត្រូវបានគេដោះស្រាយជារៀងរហូតមក...

## ការមកដល់ដោយចៃដន្យ ៖

ការមកតាំងទីរបស់ប្រទេសបារាំងនៅតំបន់ព្រៃនគរ ( ១៨៥៩ ) ដោយបន្តមកទៀតការប្រគល់អាណាខេត្តពីប៉ែកខាងកើតនៃដែនដីកូសាំងស៊ីន ព្រមទាំងច្បាប់បើកសិទ្ធិឲ្យនាវាបារាំងអាចបើកបរឡើងតាមទន្លេមេគង្គ រហូតទៅដល់ប្រទេសកម្ពុជា ( ១៨៦២ ) បានចោទជាបញ្ហាដល់អាជ្ញាធរបារាំងចំពោះរឿងខ្មែរ ។ ហេតុនោះហើយបានជាទីចុងសំរេច ក៏បានយកកម្ពុជាដាក់ជាអាណាព្យាបាលនៃប្រទេសបារាំងទៅ ( ១៨៦៣ ) ។ ភាពចលាចលរឹករវរជ្រួលច្របល់ដែលកើតមានឡើងចំពោះការបន្តរាជ្យពីព្រះអង្គឌួង ( ១៨៦០ ), ការគាំទ្រដល់ចលនារំដោះយួនចំពោះវត្តមាននៃប្រទេសបារាំងនៅទីនោះ បានជំរុញឲ្យប្រទេសបារាំងដណ្តើមយកនគរកូសាំងស៊ីនទាំងមូល(១៨៦៧) ។ ចំពោះខ្មែរទូទៅនិងជាពិសេសចំពោះខ្មែរក្រោម ការរៀបចំឲ្យមានសន្តិភាពឡើងវិញ ពីសំណាក់ប្រទេសបារាំងជាចៃដន្យចុងក្រោយបំផុត ។ ដូច្នេះតើខ្មែរក្រោមមានចំនួនទាំងអស់ប៉ុន្មានទៅ ? ។ តាមភាពខាងក្រៅ, ខ្មែរក្រោមមានចំនួនដ៏សមរម្យ ដ៏សំខាន់ណាស់ដែរក្នុងបណ្តាប្រជាជនគ្រប់ជាតិសាសន៍រស់នៅលើដែនដីកូសាំងស៊ីន គឺប្រហែលជា១៥% ( ដប់ប្រាំភាគរយនៃចំនួនប្រជាជនសរុប ) ហើយជាការពិតណាស់ទៅទៀត នៅលើដែនដីកូសាំងស៊ីន ដែលមិនសូវសំបូរប្រជាពលរដ្ឋ ដែលសរុបជាតិសាសន៍ទៅមានប្រមាណត្រឹមតែ១លានកន្លះ

ប៉ុណ្ណោះ ។ នៅស្ទើរគ្រប់ខេត្តទាំងឡាយ ដោយឡែកជាពិសេសនៅតាមអាណាខេត្តកាត់តាមទន្លេបាសាក់ ( និយាយទៅតាមន័យទូលំទូលាយ ) មានប្រជាពលរដ្ឋខ្មែររស់នៅដោយភាគច្រើនដាច់ខាត ។ គេបានប៉ាន់ប្រមាណថា មានយ៉ាងហោចណាស់២០០.០០០នាក់ដែរ ។ ទោះបីចំនួននេះហាក់បីដូចជាបំប៉ោងឲ្យច្រើនខ្លះដោយអ្នកគាំទ្រ ( ដោយសុទ្ធចិត្តឬដោយអ្នកវេទៅតាមខ្យល់ ) ដល់ការសំអាងហេតុផលរបស់គេ នូវចំពោះការទាមទារសិទ្ធិហួសមាឌរបស់សាសន៍យួននោះ ក៏ចំនួនប៉ុណ្ណោះនៅតែសមហេតុផលដដែល ។ តែការនេះវាមិនសូវជាសំខាន់ណាស់ណាពេកទេ ព្រោះថាបើសិនជាគេធ្វើការសង្កេតពិនិត្យទៅលើការវិវត្តន៍នៃកំណើនរបស់ប្រជាជនខ្មែរក្រោមវិញនោះ គេឃើញថាស្ថានភាពនៃកំណើតរបស់ខ្មែរក្រោមត្រូវស្ថិតនៅក្នុងភាពអាសន្នគួរឲ្យព្រួយបារម្ភ ដោយមានអត្រាកំណើនស្ទើរតែនៅគាំងមិនទៅមុខសោះ (avec un taux de croissance voisin de la stagnation ) ។ តើគេអាចពោលយ៉ាងណាបានទៅទៀត បើសិនជានៅកម្ពុជាក្រោម ( Kambujà Krom ) សឹងតែទទួលនូវការបំផ្លិចបំផ្លាញខ្ទេចខ្ទីដោយសង្គ្រាមជាបន្តបន្ទាប់ និងដោយការកំរើករំពើក បះបោរ បដិវត្តន៍តាំងពីជាងកន្លះសតវត្សមកហើយនោះ ហើយសហគមខ្មែរក្រោម ក៏មិនអាចរាបបញ្ចូលផងដែរ នូវជនអន្តោប្រវេសន៍ដែលហូរចូលមកជានិច្ចជាកាល ដើម្បីញាំងឲ្យចំនួនប្រជាពលរដ្ឋរបស់ខ្លួនកាន់តែមានចំនួនច្រើនឡើងយ៉ាងខ្វូវខ្វារនោះក៏ទេដែរ ។

## កំណើនឡើងវិញដ៏លំបាកនៃប្រជាជាតិមួយ

ក៏ប៉ុន្តែគេគោងតែគិតផងដែរថា នយោបាយរបស់ប្រទេសបារាំងនៅដែនកូសាំងស៊ីន បានផ្លាស់ប្តូរលក្ខណៈការរស់នៅរបស់ខ្មែរក្រោមយ៉ាងឆាប់ប្លែកអស្ចារ្យ ។ ម៉្យាងដើម្បីជួយឃិតឃោងដល់ខ្មែរក្រោម គេគោងបញ្ឈប់លែងឲ្យជនជាតិយួនហូរចូលដូចទឹកជន់មកតទៅទៀត ត្រូវទទួលនូវជនជាតិផ្សេងៗទៀតដែលរស់នៅលើទឹកដីដែនកូសាំងស៊ីន ដូចនេះរដ្ឋបាលអាណានិគមបារាំង គោងមានគុណសម្បត្តិយល់ឲ្យបានច្បាស់លាស់ និងត្រូវវិនិច្ឆ័យឲ្យឃើញជាមុននូវនយោបាយមួយខុសប្លែកមិនដូចនយោបាយ ដែលរដ្ឋបាលបារាំងបានអនុវត្តនៅលើដែនដីប្រទេសកំណើតរបស់ខ្លួននោះឡើយ (administration métropolitaine) ។ ការធ្វើ « យួនូបនិយកម្ម la viêtnamisation de la Cochinchine » លើទឹកដីនគរកូសាំងស៊ីនដ៏មានបង្កប់ស្មៀតខូច ត្រូវតែរិះរកឲ្យឃើញហេតុផល ភស្តុតាងច្បាស់លាស់ រួចបញ្ជូនទៅឲ្យតុលាការពិនិត្យពិច្ច័យ ។ រហូតមកដល់រវាងឆ្នាំ១៨៩០ នៅពេលដែលរដ្ឋបាលបារាំងនៅឥណ្ឌូចិនចាប់ផ្តើមរួមបញ្ចូលឲ្យមូលគ្នា ក៏ខ្មែរក្រោមនៅតែមិនទាន

ប្រាកដក្នុងចិត្តថា ស្ថានភាពនោះនៅមិនទាន់ស្ថិតស្ថេរ មិនទៀងទាត់នៅឡើយ ។ សក្ខីភាពដ៏សំខាន់ ត្រូវបានផ្តល់ឲ្យដោយការធ្វើកំណើនប្រជាជនដែលចាត់ចែងឡើងដោយក្រុមរដ្ឋបាលខ្លួនឯងផ្ទាល់ ។ ជាការពិតប្រាកដជាក់ច្បាស់ណាស់ចំ-ពោះខ្មែរក្រោម ទោះកិច្ចការនោះប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ឬក៏នៅប្រទេសលាវក៏ដោយ ក៏ខ្មែរក្រោមនៅតែគេចវេះចៀសចេញឆ្ងាយពីផ្នែករដ្ឋបាល ។ ទោះបីពួកគេតែងលាក់ខ្លួនពួនអាត្មាដោយរក្សាភាពជាខ្មែរយ៉ាងហ្មត់ចត់ ទោះបីពួកគេបានគេចផេះរត់ទៅពួននៅទីស្ងាត់កំបាំងពិបាកទៅរកឃើញ ឬទោះបីសំអាងលើលក្ខណៈផ្សេងៗខ្លះ ដែលគេមិនអាចយកមកជជែកវែកញែកនាពេលនេះ ទីនេះក៏ដោយ ក៏ព្រឹត្តិហេតុបានបង្ហាញយ៉ាងជាក់ច្បាស់ថាខ្មែរក្រោមមិន ដែលបានបង្ហាញខ្លួនដោយរីករាយ នៅចំពោះទង្វើស្ថិតិដែលចាត់ចែងឡើងជាផ្លូវការនោះឡើយ ។ កង្វះក្នុងរឿងនេះមានរហូតដល់ទៅ៥០%ឯណោះ ។ ការនេះជាការសំខាន់ណាស់ ក៏ប៉ុន្តែមិនមែនជាពត៌មានតែមួយគត់ ដែលជាការរាំងស្ទះគាំងមិនទៅមុខពីគោលដៅដែលផ្តល់នោះក៏ទេដែរ ។ ក្រៅពីការតែបន្លំ និងបាចពង្រាយជាបន្តបន្ទាប់ ចំនួនលេខដ-ដែលអនុញ្ញាតឲ្យគេធ្វើការពិចារណាទទួលដោយអាជ្ញាធររដ្ឋបាលបាន ។ ពោលម៉្យាងផ្សេងទៀត គឺជាការប្រាកដប្រជាណាស់ ដែលអត្រាកំណើននៃប្រជាពលរដ្ឋខ្មែរក្រោមត្រូវចុះក៏រីតយ៉ាងទាបបំផុត ។ ការកើនឡើងវិញ នៃចំនួនប្រជាពលរដ្ឋមានសភាពយឺតយ៉ាវខ្លាំងណាស់ ហើយគេគោងត្រូវការពេលវេលាច្រើនឆ្នាំទៅទៀតសំរាប់ខ្មែរក្រោមក្នុងការផ្សះដំបៅនេះ ( ការចុះខ្សោយចំនួនពលរដ្ឋ ) ដើម្បីឈោងទៅដល់ការកើនឡើងមកវិញ ។

## ការទទួលស្គាល់បីប្រការរបស់ប្រទេសបារាំង

១- ការទទួលស្គាល់ផ្នែកស្ថិតិ ( La reconnaissance statistique )

រវាងជំណាច់ឆ្នាំ១៨៨០ គឺប្រាកដជាមានការប៉ុនប៉ងប្រាថ្នាកាន់កាប់ទៅអនាគតនូវដែនដីឥណ្ឌូចិនទាំងមូលបញ្ចូលរួមគ្នារបស់ប្រទេសបារាំងនោះហើយ ដូចដែ-លបារាំងបានតែងតាំងបណ្តាញរដ្ឋបាលមួយដ៏ណែនចង្អៀតតាមបែបបស្ទឹមប្រ-ទេស ហើយដោយមានការភ័យខ្លាចតតាំងពីជីដូនជីតារៀងមក – ភ័យខ្លាចពួកយួនធ្វើការគាបសង្កត់ជិះជាន់ធ្វើឲ្យជាតិសាសន៍របស់ខ្លួនរលប់រលាយនោះហើយ ទើបបានជាខ្មែរក្រោមនាំគ្នាចាកចេញមកបង្ហាញខ្លួនដល់រដ្ឋអាជ្ញាធរ ។ ពួកគេត្រូវបង្ខំឲ្យទទួលស្គាល់ជាបន្ទាន់ដល់អាជ្ញាធរជាអ្នកកាន់អំណាច ។ នៅពេលធ្វើការជំរឿនប្រជាជនជាថ្មីម្តងៗ គេតែងកត់សម្គាល់ឃើញថា មានប្រជាពលរដ្ឋខ្មែរក្រោមកាន់តែច្រើនឡើងៗ ។ នៅពេលប្រហែលជា១០ឆ្នាំមុនបញ្ចប់សតវត្សចាស់ គេពិនិត្យ




រូបថតវត្ត « កោះកែវសិរី » ( ខេត្តព្រះត្រពាំង ) ប្រទេសកម្ពុជាក្រោម / កសាងឡើងក្នុងព.ស. ១១៥៧ ត្រូវនឹងគ.ស. ៦១៣) បានសេចក្តីថាជនជាតិខ្មែរតាំងទីនៅលើទឹកដីកម្ពុជាក្រោមរាប់សតវត្សមកហើយ គឺនៅមុនពេលសម័យមហានគរម្ល៉េះ ជាម្ចាស់ទឹកម្ចាស់ដីពិតប្រាកដ !

ឃើញថា ចំនួនប្រជាពលរដ្ឋខ្មែរក្រោមបានកើនឡើងទ្វេជាពីរក្នុងស្ថិតិ គឺឡើងដល់ទៅជាង២០០,០០០នាក់ ក្នុងរវាង១០ឆ្នាំដំបូង ( dans les premières années du XXe siècle ) ។ ជាក់ស្តែង, គេមិនត្រូវពិនិត្យមើលចំពោះតែលទ្ធផលចុងក្រោ-យបង្អស់នៃអ្នកបដិសេធឬបំបាត់ជំនឿទាំងអស់ ឬក៏មិនត្រូវជឿថា មានជនអន្តោ-ប្រវេសន៍វិលត្រឡប់ចូលមកពីព្រះរាជាណាចក្រកម្ពុជានោះក៏ទេដែរ តែនេះគ្រាន់តែជាការដាក់បន្ថែមឲ្យបានត្រឹមត្រូវឡើងវិញ នូវស្ថិតិជាផ្លូវការឲ្យស្របទៅតាមភាពពិតនៃកំណើនប្រជាជន ដូចជាដែលព្រឹត្តិហេតុបែបនេះក៏បានកើតឡើងស្របគ្នានៅប្រទេសកម្ពុជានោះផងដែរ ។ ម៉្យាងវិញទៀត អត្រាកំណើននៃសហគមខ្មែរក្រោម ក៏មានភាពប្រហាក់ប្រហែលសមរម្យទៅតាមការពិតណាស់ដែរ ហើយក៏ជាការសង្កេតឃើញដោយងាយថា បានកើនឡើងវិញជាវិជ្ជមានផងដែរនាចុងសតវត្ស

នេះ ពោលគឺតោងកើនឡើងចាប់ពី០.៥០% (កន្លះភាគរយ) ឡើងទៅក្នុង១ឆ្នាំៗ ។

អំណើះតទៅ ប្រភពជាផ្លូវការបានកត់សម្គាល់ឃើញយ៉ាងទៀងទាត់ថា មានការកើនឡើងជាដរាបចំពោះសហគមខ្មែរក្រោម ។ ដោយស្របទៅនឹងអត្រាកំណើនដែលមានការជឿនលឿនទៅមុខ ដូចនេះតោងគិតថាអត្រាកំណើននៃសហគមខ្មែរក្រោម ក៏តោងឡើងលើសពី២% (ពីរភាគរយ) ដែរក្នុង១ឆ្នាំនាមុនសង្គ្រាមលោកលើកទី២ គឺបានសេចក្តីថា មានចំនួនប្រជាជនកើនឡើងលើសប្រហែល ១០,០០០នាក់ដែរក្នុង១ឆ្នាំ ។ សហគមខ្មែរក្រោមបានក្លាយទៅជាសហគមមួយប្រកបដោយការកើនឡើងស្របតាមវិចារណញ្ញាណនិងដោយឋាមពល ( une communauté démographiquement saine et dynamique ) ដែលកំពុងតែឈោងទៅចាប់មុខនាទីរបស់ខ្លួនឡើងវិញ ដោយត្រូវរ៉ូវ, ដោយព្រៀងគ្នានៅក្នុងដែនដីកូសាំងស៊ីន ហើយនាពេលអនាគតពាក់កណ្តាលសតវត្សនេះឯង នឹងប្រកបដោយថាមពលដ៏ទម្ងន់មួយមានប្រជាពលរដ្ឋដល់ទៅកន្លះលាននាក់ឯណោះ ។

២- <u>ការទទួលស្គាល់ផ្នែកអត្តសញ្ញាណវប្បធម៌</u> **( La reconnaissance de l' Identité Culturelle )** ៖

នៅក្នុងអត្ថបទស្វែងរកការពិត « ពីលក្ខណៈនៃកំណើនជាក់ស្តែង » របស់ខ្មែរក្រោម រដ្ឋបាលអាណានិគមបារាំង ដោយឃោលទៅលើនយោបាយផ្នែកវប្បធម៌ និងមុខនាទីរបស់ខ្លួនក្នុងកិច្ចការរួមបញ្ចូលទៅក្នុងផ្នែកនយោបាយនៅក្នុងដែនដីឥណ្ឌូចិនទាំងមូល ក៏បានខិតខំធ្វើឲ្យសហគមខ្មែរក្រោមរឹតតែមានថាមពលឡើងវិញ ។ ដោយបន្តទៅទៀតនូវយុទ្ធសាស្ត្រក្នុង « បេសកកម្មធ្វើឲ្យមានការចំរើនស៊ីវិល័យ » របស់ខ្លួនឡើងនោះ រដ្ឋអំណាចបារាំងក៏បានរៀបចំចាត់ចែងធ្វើឲ្យជីវភាពផ្នែកវប្បធម៌កំរើកឡើងវិញនៅក្នុងការរស់នៅជាសាមញ្ញ និងបង្ខិតបង្ខំឲ្យប្រជាពលរដ្ឋបញ្ជូនកូនចៅទៅកាន់សាលារៀន ។ ជាការពិតប្រាកដណាស់ទៅហើយថា កាលណាគេនិយាយអំពីបញ្ហាខ្មែរក្រោមនៅដែនដីកូសាំងស៊ីន គេត្រូវស្គាល់នូវនូវការពិតថា ៖ ពុម្ពឬបែបបទតាមរបៀបឃ្មួនដែលគេដាក់ជាគំរូ ( standard ) នៅដែនដីកូសាំងស៊ីននោះ វាមិនអាចសំរបសំរួលទៅបានទាល់តែសោះចំពោះ ខ្មែរក្រោម ។ ម្ល៉ោះហើយរដ្ឋអំណាចបារាំងគ្មានការជ្រើសរើសឯណាដទៃទៀត ក្រៅពីយកតាមក្បួនច្បាប់អប់រំដល់ខ្មែរនៅឯព្រះរាជាណាចក្រកម្ពុជា សំរាប់ផ្តល់ឲ្យដល់ខ្មែរក្រោម ។ ហើយបន្តិចម្តងៗ តាមរយៈសាលាវត្ត ក៏មានផ្សព្វផ្សាយអក្សរខ្មែរដែលបោះពុម្ព ផ្សាយពីវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិតនៅក្រុងភ្នំពេញ និងតាមរយៈសាលាវត្តដដែល ក៏មានការបង្កើតក្របខ័ណ្ឌខ្មែរក្រោមនៅឯប្រទេសកម្ពុជា ។ល។ រដ្ឋអំណាចអាណានិគមបារាំងក៏យល់ឃើញថា ត្រូវតែទទួលស្គាល់ក្នុងពេលដំណា

លក្ខណៈនោះនូវអត្តសញ្ញាណផ្នែកវប្បធម៌ដល់ខ្មែរក្រោម ដែលគ្មាននរណាអាចប្រឆាំងជំទាស់បានឡើយ តាំងពីច្រើនឆ្នាំណាស់មកហើយ ។

ស្របពេលជាមួយគ្នានោះផងដែរ ដោយសារការធ្វើគមនាគមន៍ក៏កាន់តែស្រួលជាលំដាប់ ពីដែនដីកូសាំងស៊ីនទៅកាន់ព្រះរាជាណាចក្រកម្ពុជា ក៏ជាហេតុញ៉ាំងឲ្យមានការប្តូរកេរិតវប្បធម៌ កេរិតប្រជាប្រិយភាពកាន់តែកើតមានឡើងដំណាលគ្នារវាងពលរដ្ឋខ្មែរក្រោម និងជនរួមឈាមរបស់គេគឺខ្មែរនៅព្រះរាជាណាចក្រ ។ នៅដំណាលពេលដែលគេយកបានរាជាណាចក្រ ធ្វើជាអាណានិគមនោះ ក៏គេសង្កេតឃើញថា មានវរៈជននិងរបៀបស្លៀកពាក់ របៀបរស់នៅរបស់ខ្មែរក្រោម ហើយមិនមានត្រឹមតែជនប៉ុន្មាននាក់ដែលបានហាត់ហ្វឹកហ្វឺនអប់រំ តាមគន្លងអាណានិគមបារាំងនោះឡើយ អ្នកខ្លះបានទាំងត្រឡប់ឡើងវិញតាមទន្លេមេគង្គទៅកម្ពុជា ដើម្បីបំរើការងារជាអ្នកបកប្រែភាសា, ជាទីប្រឹក្សាបច្ចេកទេស, ជាបុគ្គលិកក្របខ័ណ្ឌ, ជាភ្នាក់ងារសំរាប់តែអនុវត្តតាមតែគេប្រើ ឬក៏ជាមនុស្សជំនិតដូចជាសឺន-ឌៀបជាដើម...។ យើងក៏គួរបញ្ជាក់ឡើងវិញផងដែរថា វចនានុក្រមបារាំង-ខ្មែរដំបូងបង្អស់ត្រូវបានធ្វើឲ្យកើតឡើងជារូបរាងដោយខ្មែរក្រោមម្នាក់ ៖ សឺន-ឌៀប (**Aymonier : Etienne – Dictionnaire Khmer Français, autographié par Son Diep** ) ហើយប្រលោមលោកសម័យទំនើបចេញផ្សាយលើកដំបូងបំផុត គឺរឿង « សូផាត » ដោយរីម-គិន ក៏បាន ត្រូវរៀបចំបោះផ្សាយនៅដែនដីកូសាំងស៊ីន ( **Cholon : Imprimerie Man Sanh 1941** ) ។ សឺន-ឌៀបបានត្រូវគេចាត់ទុកថា « ជាគន្លឹះនៃអំណាច » នៅប្រទេសកម្ពុជានាដើមសតវត្សនោះ ( គេបរិយាយយ៉ាងក្បោះក្បាយក្នុងសៀវភៅពីរក្បាលៈ **Le Cambodge et la colonisation française** និង **Histoire d'une colonisation sans heurt ( 1897-1930)** ។ ឯសឺន-ង៉ុកថាញ់វិញ ដែលជាអ្នកក្រោកឡើងណែនាំខ្មែរបង្កើតចលនាឥស្សរៈប្រឆាំងនឹងរដ្ឋអំណាចបារាំង និងដើម្បីទាមទារឯករាជ្យជូនមាតុប្រទេស តាំងពីឆ្នាំ១៩៣០តរៀងមកនោះ ក៏ជាខ្មែរក្រោមដែរ ។ **Jean Claude Pomonti** ក៏បានរៀបរាប់ពីមុខកងអតិតខ្មែរសេរី និងកងទ័ព **Mike Force** ដែលបានចូលមកជួយជាកម្លាំងទ័ពជាតិក្នុងសម័យសាធារណរដ្ឋផងដែរ ។

<u>កំណត់អ្នកបកប្រែ</u> ៖ គិតសព្វគ្រប់ទៅខ្មែរក្រោម បានត្រឹមតែយកកម្លាំងពលំ គំនិតប្រាជ្ញាមកជួយយកអាសារគេគ្រប់កាលសម័យ តែពេលគេដល់ត្រើយហើយកាលណា គេសើយគួថដាក់, គេស្តោះទឹកមាត់, គេប្រមាថកាតទាន, គេចោទថាមកចង់មកដណ្តើមអំណាចគេ, ធ្វើគុណដល់គេត្រឡប់ជាបានទោស ។ ខ្មែរក្រោមរងទុក្ខរាប់សតវត្សមកហើយ តើអន្តរជាតិល្មមបើកភ្នែកមើលខ្លះៗផងបានទេ (??) ។

កាលសម័យអាណានិគមបារាំង ខ្មែរក្រោមស្មោះត្រង់បំផុតចំពោះនាយចៅហ្វាយបារាំង ។ ទ័ពខ្មែរក្រោមទៅត្រង់កន្លែងណា យៀកមិញត្រូវរលាយកន្លែងនោះ ។ ជួយបារាំងគ្រប់បែបយ៉ាង ដល់ទីបំផុតបារាំងលើកដីកូសាំងស៊ីនប្រគល់ទៅស្ដេចបាវ-ដាយ...ចុកឈាម!! ។ ក្នុងរាជ្យជប៉ុនចូលត្រួតត្រាអាស៊ីប៉ែកអគ្នេយ៍ ខ្មែរក្រោមជួយជប៉ុនទៀត ។ លោកសឺន-ង៉ុកថាញ់ត្រូវជប៉ុនលើកឲ្យឡើងជារដ្ឋមន្ត្រីទី១នៅស្រុកខ្មែរបានប៉ុន្មានខែ ត្រូវបារាំងចាប់ច្រកគុកនៅខេត្ត Poitiers ។ ចូលមកដល់សករាជអាមេរិកាំង ក៏បើសិនជាកុំបានកងកម្លាំង Mike Force, កងកម្លាំងពិសេស (Special Force និងកងកម្លាំងអតិតខ្មែរសេរីរបស់លោកសឺន-ង៉ុកថាញ់ ម៉្លេះសមអាមេរិកាំងយូរយារណាស់មកហើយ...។ ក្នុងនយោបាយខ្មែរសព្វថ្ងៃ ខ្មែរក្រោមមានវត្តមាននៅគ្រប់គណបក្ស គ្រប់និន្នាការនយោបាយ តែបានត្រឹមបំរើគេ ព្រោះតែការស្មោះត្រង់ចំពោះជាតិពេកទៅ...។ លោកថាច់-ជាត្រូវខ្មែរគ្នាឯងសម្លាប់ព្រោះតែស្រឡាញ់ជាតិហួសហេតុពេកក្នុងចំណោមហ្វូងឆ្កែចចកដីសែនពុករលួយ ... ទោះបីមុនដាច់ខ្យល់ស្លាប់ហើយក៏ដោយ ក៏នៅតែឆ្លៀតផ្ដែផ្ដាំជាចុងក្រោយបង្អស់ ៖ « សូមបងប្អូនខ្មែរកុំឈ្លោះទាស់ទែងកាប់សម្លាប់គ្នា... សូមរួបរួមសាមគ្គីគ្នា ប្រជាងទង់សាធារណរដ្ឋឲ្យដើរទៅមុខឆ្ពោះទៅរកជោគជ័យជាស្ថាពរ... » ) ។

អំណើះតទៅ ប្រជាជាតិនេះត្រូវតែរកឲ្យឃើញឡើងវិញ នូវឯកភាពជាតិដំណាលពេលដែលរកឃើញអត្តសញ្ញាណផ្នែកវប្បធម៌របស់ខ្លួន ( Son unité en même temps que son identité culturelle ) ឡើងវិញ ។

៣- <u>ឆ្ពោះទៅរកការទទួលស្គាល់ផ្នែកនយោបាយ</u> **Vers la reconnaissance politique** ៖

វាជាការពិតណាស់ទៅហើយថា ការលេចចេញជារូបរាងឡើងដែលប្លែកៗពីគ្នា នៃការឆ្លុះឆ្លាយផ្នែកមនោសញ្ចេតនានៅក្នុងដែនដីកូសាំងស៊ីន ដែលតាមទ្រឹស្ដីគេចាត់ទុកថា ជារបស់យួនទៅហើយនោះ បានចោទជាបញ្ហាដល់ផ្នែករដ្ឋបាល ។ មនុស្សក្នុងសង្គមទាំងឡាយដែលត្រូវបរាជ័យ ដែលមានការអៀនខ្មាស់ ដែលគាំងមិនជឿនទៅមុខ, ដែលមិនបានទទួលស្គាល់កំហុសឬទទួលសារភាព, ដោយមិនគិតគូរទៅលើមនុស្សរាប់ម៉ឺនសែននាក់នោះ គេមិនបានចាត់ចែងកាន់កាប់ឲ្យមានលក្ខណៈដូចមនុស្សជនជាតិភាគតិច ដែលមានចំនួនដល់ទៅរាប់សែន-រាប់លាននាក់ ដែលកំពុងច្បាំងដណ្ដើមយកមកវិញ ប្រកបទៅដោយថាមពលស្វិតស្វាញផ្នែកវប្បធម៌ និងផ្នែកកំណើនឡើងនៃប្រជាជននោះឯណា ! ។ ជនជាតិបារាំងភាគខ្លះដែលយល់ស្រប ដែលយោគយល់ដោយអនុគ្រោះដល់ខ្មែរក្រោមនោះ ត្រូវគេលេបស្រូបបាត់ រួចហើយពួកគេក៏នាំគ្នារៀបចំចាត់វិធានការណ៍ពញ្ញាក់ស្មារតីរដ្ឋអំ




សាលារៀននៅក្នុងវត្ត « កងច័ក្រការាម » ភូមិធ្លក ស្រុកភ្នំដាច់ ខេត្តព្រះត្រពាំង ( ប្រទេសកម្ពុជាក្រោម ) – សំរាប់ជនជាតិខ្មែរក្រោម ទីវត្តអារាមមិនត្រឹមតែជាជំរកនៃព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ក៏ជាកន្លែងថែរក្សាវប្បធម៌ជាតិខ្មែរឲ្យរស់រវើកជានិច្ចថែមទៀតផង ។ ជនជាតិខ្មែរក្រោមរបស់យើងភាគច្រើន បានទទួលនូវការរៀនសូត្រអក្សរខ្មែរ តាមវត្តអារាមប៉ុណ្ណោះ ។ មានពេលខ្លះ ពួកអាជ្ញាធរយួនបានបង្ខិតបង្ខំមិនឲ្យបងប្អូនយើងកាន់ព្រះពុទ្ធសាសនា និងរៀនសូត្រអក្សរខ្មែរយើងទេ ។ ហេតុដូច្នេះហើយ បានជាគេសង្កេតឃើញមានបះបោររើបំរះងើបឡើងធ្វើការតស៊ូបង្ហូរឈាមជាច្រើនលើកច្រើនសារ... ។ នេះហើយជាជីវិតដ៏លំបាកលំបិននៃជនជាតិត្រូវគេជិះជាន់សង្កត់សង្កិន។ បងប្អូនយើងធ្លាប់បានហែលឆ្លងកាត់នូវការពិសោធន៍ឈឺចាប់ខ្លោចផ្សាំនេះមានពាក្យចង់ក្រើនរំលឹកប្រាប់បងប្អូននៅឯមាតុប្រទេសថា «សូមប្រុងប្រយ័ត្ន កុំភ្លេចខ្លួនចាញ់កល្បសត្រូវ រួចបែរមកសម្លាប់បងប្អូនខ្លួនឯងដូច្នេះ !

ណាចឲ្យទទួលស្គាល់សិទ្ធិផ្នែករដ្ឋបាលដោយឡែកដល់ខ្មែរក្រោម រហូតទៅដល់ទុកឲ្យខ្មែរក្រោមរក្សាសញ្ជាតិដើមរបស់ពួកគេទៅទៀតផង ។ ការទាមទារនោះរឹតតែមានប្រសិទ្ធិភាពកាន់តែខ្លាំងឡើងទៅទៀត នៅពេលដែលគេចាប់ផ្តើមស្រាវជ្រាវរាវរកបូរាណវត្ថុជាប្រវត្តិសាស្រ្ត និងជាផ្នែកខាងសិល្បៈប្រគល់ឲ្យដល់ខ្មែរក្រោម នូវសិទ្ធិរបស់ខ្លួនក្នុងឋានៈជាម្ចាស់ដើមនៅលើទឹកដីកម្ពុជាក្រោម ( leurs

**droits historiques sur le Cambodge d'aval** ) ហើយដែលទង្វើបែបនេះ ជាហេតុញ៉ាំងឲ្យខ្មែរក្រោមទទួលនូវសិទ្ធិស្របច្បាប់យ៉ាងដាច់ខាត ថាជាអ្នកកាន់កាប់ទឹកដីត្រង់នេះ ( **et donc une manière de légitimité absolue de l'occupation du sol...**) ។ *ការសិក្សាស្រាវជ្រាវទៅលើបូរាណប្រាសាទនានាមុនសម័យអង្គរ* ( **pré-Angkoriens** ) *រួចការជីកកាយរកវត្ថុបូរាណនានាក្នុងសម័យហ្វូណន់* ( **Founan** ) *បានធ្វើឲ្យគេស្គាល់កាន់តែច្បាស់ណាស់ទៅទៀត ពីវត្តមាននិងការជឿនលឿនទៅ មុខនូវតំបន់និងភូមិភាគខ្លះៗក្នុងដែនដីកូសាំងស៊ីន ដែលមានរយៈពេលជាងរាប់ រយឆ្នាំមុនការចូលមកដល់នៃជនជាតិយួនទៅទៀត* ( **L'étude des sites pré-angkoriens, puis la prospection systématique de Fou-Nan, mettaient en évidence l'existence d'un développement avancé de certaines régions de la Cochinchine plus d'un millénaire avant l'arrivée des vietnamiens !** )។ *ខ្មែរក្រោមមិនត្រឹមគ្រាន់តែចាត់ទុក ថាជាជនជាតិភាគតិចដែលគេត្រូវតែទទួលស្គាល់ឡើងវិញ នូវសិទ្ធិផ្នែកវប្បធម៌និងផ្នែករដ្ឋបាលដ៏ជាការធម្មជាតិខ្លះៗប៉ុណ្ណោះឡើយ តែខ្មែរក្រោមនឹងត្រូវបានក្លាយជាអង្គធាតុដ៏សំខាន់និងចាំបាច់បំផុត ជាប្រជាជាតិមួយយ៉ាងពិតប្រាកដ នេះបើនិយាយទៅតាមន័យទូលំទូលាយច្បាស់លាស់* ( **Les Khmers-Krom n'étaient plus seulement cette minorité à laquelle on se devaient de reconnaître certains droits culturels et administratifs élémentaires, ils redevenaient une composante essentielle d'une NATION au sens plein du terme** ) ។

បើគេត្រិះរិះពិចារណាឲ្យបានត្រឹមត្រូវល្អិតល្អន់នោះ ឃើញថាការស្រង់យកមកវិញនូវសិទ្ធិផ្នែកនយោបាយ ដើម្បីផ្ដល់ប្រគល់ជូនខ្មែរក្រោម ជាករណីចាំបាច់ចៀសពុំបាន ( **inévitable** ) ។ តើបន្ទាប់ពីស្ទឹងត្រែង, ម្លូព្រៃ, សៀមរាប, បាត់ដំបង ។ល។ តើរាជអំណាចខ្មែរ ( **la couronne cambodgienne** ) មានមធ្យោបាយនឹងបន្តការទាមទារដែនដីកូសាំងស៊ីន យកមករួមបញ្ចូលក្នុងមាតុភូមិដើមរបស់ខ្លួនផងដែរបានឬទេ (??) ។

# នាពេលវិបត្តិនានា LE TEMPS DES CRISES

## ការកើនឡើងនៃវិបត្តិ La montée de la crise ៖

ការទទួលស្គាល់នូវសិទ្ធិទាំងអម្បាលមាណនេះ នឹងក្លាយទៅជាមានសារៈសំ-ខាន់ណាស់ បើប្រៀបធៀបទៅនឹងការទទួលស្គាល់សហគមខ្មែរក្រោម ដោយ

ហេតុតែមានការបន្តហូរចូលមិនឈប់ឈរនៃក្រុមអន្តោប្រវេសន៍ចិននិងយួន ព្រមទាំងអត្រាកំណើនយ៉ាងខ្លាំងក្លានៃជនជាតិសាសន៍ទាំងពីរនោះ ។ ជោគជ័យរបស់ខ្មែរក្រោម នឹងគ្រាន់តែក្លាយទៅជាជោគជ័យបែបបទ Pyrrhus ដូច្នោះឯង នាពេលឆាប់ៗខាងមុខនេះ ។ បើប្រសិនជាគេអាចសង្ឃឹមថា នាជំណាច់សតវត្សទី១៩នេះ ចំនួនប្រជាពលរដ្ឋខ្មែរក្រោមអាចនឹងកើនឡើងដល់ទៅជិត១០%នៃចំនួនប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅលើដែនដីកូសាំងស៊ីន ។ ដោយហេតុថាមុនសង្គ្រាមលោកលើកទី២ ចំនួនប្រជាពលរដ្ឋខ្មែរក្រោមមិនជាកើនឡើងណាស់ណាពេកទេ គឺប្រមាណជាង៧%ប៉ុណ្ណោះ ។ នាពេលនោះ ការរស់រានមានជីវិតរបស់ពួកគេ ក៏សំអាងតែទៅលើការទទួលស្គាល់នូវសិទ្ធិក្នុងផ្នែកនយោបាយ ។ ហាក់បីដូចជាមានកិច្ចការធានាគាំទ្រពីសំណាក់មជ្ឈដ្ឋានបារាំងខ្លះៗដែរ ដោយអនុគ្រោះទៅលើគំនិតនេះ ស្ដីពីលក្ខន្តិកៈពិសេសដែលនឹងផ្ដល់ឲ្យដល់ដែនដីកូសាំងស៊ីននៅក្នុងបណ្ដាជនជាតិនៅឥណ្ឌូចិនទាំងមូល ដោយចាត់ទុកជាកិច្ចសន្យាមួយ ។ រួចហើ




រូបថតក្លោងទ្វារវត្ត « ព្រះពន្លាជ័យ » ( ខេត្តព្រះត្រពាំង ) ប្រទេសកម្ពុជាក្រោម

យតាមរយៈវាសនានៃជនជាតិខ្មែរក្រោមកន្លះលាននាក់ គួសវាសបានជាកម្លាំងធាតុមួយក្នុងការថ្លឹងឲ្យស្មើគ្នាឡើងវិញផ្នែកយុទ្ធសាស្ត្រចំពោះកងកម្លាំងទាំងអស់នៅដែនដីឥណ្ឌូចិននាភូមិភាគខាងត្បូង ។

តែជាកុសល ផលវិបាកនៃសង្គ្រាមលោកលើកទី២, ការចាប់ផ្តើមសង្គ្រាមនៅឥណ្ឌូចិន និងការទទួលនូវឯករាជភាពនៃរដ្ឋនានាក្នុងដែនឥណ្ឌូចិន មិនជាការអនុគ្រោះដល់កិច្ចចរចាគ្នា, ពិបាកតម្រូវចិត្ត ហើយដែលតម្រូវឲ្យគូភាគីទាំងអស់ប្រកបដោយឆន្ទៈស្រៀវស្រួចពិចារណាស្របទៅតាមលក្ខណៈស្របច្បាប់នៃប្រវត្តិសាស្ត្រ ដោយគោរពទៅលើផ្នែកវប្បធម៌ ហើយថែមទាំងតម្រូវឲ្យមានការរួបរួមពឹងពាក់គ្នា ចងបាច់គ្នា នៅក្នុងតំបន់ភូមិភាគនេះទៀតផង ។ ក៏ប៉ុន្តែអនាគតកាលនឹងបង្ហាញឲ្យឃើញនាពេលឆាប់ៗនោះថា ភាពអង់អាចស្វាហាប់នៃរដ្ឋថ្មីៗនោះ មិនមែនស្ថិតនៅលើមនោគមវិជ្ជាដ៏បូរំបូរាណបែបអធិរាជានិយម និងបែបបទភពផែនដីនោះ ដែលគេតែងប្រគល់អំណាចសិទ្ធិអ្វីមួយដោយស្មោះទៅលើស្វ័យភាព និងទៅលើលក្ខណៈដ៏ចាំបាច់ខុសប្លែកៗគ្នានោះឯណា ? ទោះបីមានការយល់ស្របតាមលក្ខណៈដ៏ត្រឹមត្រូវរបស់ព្រះរាជាក៏ដោយ ក៏ប៉ុន្តែទៅលើការស្រឡាញ់ពូជសាសន៍, ការធ្វើបដិវត្តន៍ និងទៅលើឆន្ទៈស្របគ្នាជាឯកច្ឆន្ទឯណោះទេតើ !! ។

## ការបដិសេធមិនទទួលស្គាល់ការពិត២លើក ៖

ដោយមិនអាចទទួលស្គាល់ភ្លាមៗដល់ជនជាតិខ្មែរក្រោមនៅដែនកូសាំងស៊ីនដោយការផ្តល់នូវស្វ័យភាពយ៉ាងទូលំទូលាយតាមបែបបទរដ្ឋធម្មនុញ្ញ- ដោយហេតុតែកាលៈទេសៈមានភាពច្របូកច្របល់- គេនឹងសង្ឃឹមថារដ្ឋអំណាចវៀតណាមដែលទើបនឹងបានទទួលនូវឯករាជភាពថ្មីៗនោះ នឹងជ្រើសរើយកផ្លូវនៃកិច្ចចរចាគ្នា និងដោយអនុវត្តនយោបាយដោយពឹងផ្អែកទៅលើការពិសោធន៍ ( pratiquer une politique empirique ) និងដោយពឹងទៅលើភាពទន់ភ្លន់ ។ រដ្ឋអំណាចបានទទួលបន្ទុកជាត់ចែងរឿងនេះដោយថ្លឹងថ្លែងពិចារណារួចជាស្រេច តែត្រឡប់ទៅជាបោះបង់កិច្ចការដ៏ប្រាកដប្រជានេះទៅកៀនជញ្ជាំងទុកចោលរហូត ។ ដើម្បីនាំយករឿងនេះឆ្ពោះទៅដល់លទ្ធផលក្នុងការអនុវត្តន៍ជាក់ស្តែងរបស់ពួកគេបាន តោងធ្វើឡើងតាមរយៈកិច្ចចរចាគ្នាលើវិស័យសិទ្ធិផ្នែកវប្បធម៌ខ្លះ និងតាមរយៈល្បិចកលោបាយបំប៉ោងស្ថិតិរីកធំធាត់បន្តិច ដោយមានអាថ៌កំបាំងធ្វើយ៉ាងណាឲ្យកំណើនប្រជាជនកាន់តែមានចំនួនច្រើនឡើង ដើម្បីឲ្យមាននយោបាយទាមទារដណ្តើមយកទឹកដីនេះពីរដ្ឋកម្ពុជា ។ ឯចម្លើយរបស់កម្ពុជាមិនសូវជាប្លែកខុសគ្នាប៉ុន្មានដែរ គឺគេរក្សាគំនិតនេះឲ្យមានភាពនៅគ្រប់ពីលើក្នុងកិច្ចដណ្តើមយកទឹកដី

និងតាមផ្លូវនយោបាយឲ្យបោះជំហានកាន់តែលឿនទៅមុខ រួចទើបវិលត្រឡប់មកចោទជាបញ្ហាឲ្យបានរឹតតែស្របច្បាប់ ចំពោះវត្តមាននៃពលរដ្ឋយួននៅលើទឹកដីកូសាំងស៊ីននោះ ។ ហើយដរាបណាមានអន្តរាគមន៍ក្នុងវិស័យកំណើនប្រជាពលរដ្ឋដោយលំអៀង គេក៏ចាត់ទុកជាក្បួនច្បាប់យកជាការស្រេច ។ សាធារណៈមតិខ្មែរមិនអាចបង្កើនចំនួនប្រជាជនឲ្យប៉ោងធំតទៅទៀតបានឡើយ យ៉ាងហោចណាស់ត្រឹមតែតំរែតំរង់ត្រឹមខួងលានធាក់ប៉ុណ្ណោះ ចំពោះសហគមខ្មែរក្រោមទាំងអស់ ។ បើសិនជាគេចង់នាំយកបញ្ហាខ្មែរក្រោមនេះមកចោទជាបញ្ហានោះ វាជាការពិតប្រាកដណាស់ទៅហើយថា ក្នុងដំណាក់កាលនេះ គេមិនអាចដោះស្រាយទៅបានឡើយតាមផ្លូវសន្តិភាព...។

## តុល្យការតាមផ្នែកស្ថិតិ Bilan Statistique ៖

ភាពមិនទាក់ទងគ្នានៃប្រភពដែលផ្តល់ឲ្យមកនោះ ហាក់បីដូចជាមិនមានភាពទៀងទាត់ទាល់តែសោះ ។ នៅពេលណាការកត់ត្រាចូលទៅក្នុងលំនាំនៅជុំវិញព្រឹត្តិការណ៍រួចរាល់អស់ហើយ វាប្រាកដជានាំឲ្យគេសំរេចយកតាមដោយស្រួល ឬនៅមានការកែតម្រូវដោយលើសឬខុសពីនោះ ។ គេត្រូវពឹងពាក់ថែមទៀត នូវចំណុចដ៏សំខាន់ៗផ្សេងៗទៀតទុកជាសញ្ញាចំណាំដែលទាក់ទងទៅនឹងស្ថានភាពមាតុភូមិដើមគឺ រាជាណាចក្រកម្ពុជា ដែលជាការទាញពន្លាយន័យកាន់តែវែងឆ្ងាយតទៅទៀត ។ វាជាការពិតប្រាកដណាស់ហើយថា លទ្ធផលដែលគេបានទទួលមកនោះ វាគ្មានតម្លៃអ្វីពិតជាក់ស្តែងទេនៅក្នុងស្ថិតិ ។ វាគ្រាន់តែជាសម្មត្តិកម្ម- សេចក្តីសន្មត់មុន ( hypothèse ) តែប៉ុណ្ណោះ សំរាប់បំរើការងារត្រិះរិះពិចារណាទៅលើអ្វីៗដែលបានផ្តល់រួចមកហើយៗដែលគេអាចធ្វើការជជែកវែកញែកពិគ្រោះគ្នាបានយ៉ាងទូលំទូលាយ ។ សំនួរជាច្រើនប្រការនៅតែបានចោទសួរដដែល ។ ដូចជាតើគេត្រូវរាប់គិតចូលក្នុងបញ្ជីយ៉ាងណាទៅ ចំពោះកូនកាត់ចិន-ខ្មែរ ហើយដែលគេបានធ្វើខ្លួនគេឲ្យក្លាយទៅជាខ្មែរអស់ទៅហើយនោះ ? ។ តើខ្មែរក្រោមទាំងអស់បានត្រូវគេធ្វើជំរឿនពិតប្រាកដមែនទែនហើយឬនៅ ? សូម្បីតែនៅសម័យដែលបារាំងត្រួតត្រានោះក៏ដោយ ? បើទោះបីគេមិនអាចប្រកែកបានថា មានខ្មែរក្រោមខ្លះដែរបានចូលសញ្ជាតិជាយួននោះ ក៏គេមិនអាចគិតថានៅតំបន់ភូមិភាគខ្លះនៃដែនដីកូសាំងស៊ីន ដែលនៅជាខ្មែរនោះក៏មានជនជាតិយួនភាគខ្លះ មាននិន្នាការប៉ុងប្រាថ្នាចង់ចូលសញ្ជាតិជាខ្មែរដែរ ?? ។ល។

ដូច្នេះវានៅសល់តែតារាងដែលយើងលើកយកមកបង្ហាញតែប៉ុណ្ណោះ ដោយសំអាងទៅលើអំណោយផ្តល់ឲ្យដោយពិតប្រាកដ ( se fonde sur des données

concrètes et traduit une certaine logique statistique ) ហើយដែលបានបង្ហាញនូវភាពសមរម្យទៅតាមស្ថិតិ ។ ទោះបីមានការកែសំរួលខ្លះៗក៏ដោយ ក៏តារាងនោះបានបង្ហាញនូវរូបភាពដ៏មធ្យម ដែលគេអាចចាត់ទុកថា ជាការវិវត្តន៍ដ៏ត្រឹមត្រូវនៃជនជាតិខ្មែរទាំងឡាយរស់នៅលើដែនដីកូសាំងស៊ីន ស្របតាមរយៈការកំណើនឡើងជាលំដាប់ ។ យើងសូមបន្ថែមជាចុងក្រោយបង្អស់ថា ការទាញពន្លាយន័យ ( les extrapolation ) នាចុងពាក់កណ្ដាលសតវត្សទី២០នោះ ឥតបានគិតផងទេពីផលវិបាកនៃការកើនឡើងឬស្រកចុះរបស់ប្រជាពលរដ្ឋនៅសម័យសង្គ្រាមឥណ្ឌូចិន ( des Guerres d'Indochine ) ព្រោះការនោះមកដល់ពេលបច្ចុប្បន្ន ហាក់បីដូចគេមិនសូវយកចិត្តទុកដាក់ផងទេ ។ ការទាញពន្លាយន័យនោះឯងជាការមិនអនុញ្ញាតឲ្យគេគូសបញ្ជាក់បង្ហាញផងទេថា ក្នុងបញ្ជីដែលបានកត់ត្រា ថាមានខ្មែរក្រោមទាំងអស់១លានកន្លះនៅដំណាច់ឆ្នាំ១៩៨០ ។ អង្គធាតុផ្សែផ្សំ ( la composante ) ខ្មែរក្រោម បន្ទាប់ពីមានភាពបាត់បង់ប្រជាជនមួយចំនួនក្រោយពីរដ្ឋប្រ-



រូបថតក្លោងទ្វារវត្ត « ចំបក់មាស » ភូមិធ្លក ខេត្តព្រះត្រពាំង (កម្ពុជាក្រោម)

តុល្យការតាមផ្នែកស្ថិតិ Bilan Statistique ៖

ភាពមិនទាក់ទងគ្នានៃប្រភពដែលផ្តល់ឲ្យមកនោះ ហាក់បីដូចជាមិនមានភាពទៀងទាត់ទាល់តែសោះ ។ នៅពេលណាការកត់ត្រាចូលទៅក្នុងលំនាំនៅជុំវិញព្រឹត្តិការណ៍រួចរាល់អស់ហើយ វាប្រាកដជានាំឲ្យគេសំរេចយកតាមដោយស្រួល ឬនៅមានការកែតម្រូវដោយលើសឬខុសពីនោះ ។ គេត្រូវពឹងពាក់ថែមទៀត នូវចំណុចដ៏សំខាន់ៗផ្សេងៗទៀតទុកជាសញ្ញាចំណាំដែលទាក់ទងទៅនឹងស្ថានភាពមាតុភូមិដើមគឺ រាជាណាចក្រកម្ពុជា ដែលជាការទាញពន្លាយន័យកាន់តែវែងឆ្ងាយតទៅទៀត ។ វាជាការពិតប្រាកដណាស់ហើយថា លទ្ធផលដែលគេបានទទួលមកនោះ វាគ្មានតម្លៃអ្វីពិតជាក់ស្តែងទេនៅក្នុងស្ថិតិ ។ វាគ្រាន់តែជាសម្មត្តិកម្ម- សេចក្តីសន្មត់មុន ( hypothèse ) តែប៉ុណ្ណោះ សំរាប់បំរើការងារត្រិះរិះពិចារណាទៅលើអ្វីៗដែលបានផ្តល់រួចមកហើយៗដែលគេអាចធ្វើការជជែកវែកញែកពិគ្រោះគ្នាបានយ៉ាងទូលំទូលាយ ។ សំនួរជាច្រើនប្រការនៅតែបានចោទសួរដដែល ។ ដូចជាតើគេត្រូវរាប់គិតចូលក្នុងបញ្ជីយ៉ាងណាទៅ ចំពោះកូនកាត់ចិន-ខ្មែរ ហើយដែលគេបានធ្វើខ្លួនគេឲ្យក្លាយទៅជាខ្មែរអស់ទៅហើយនោះ ? ។ តើខ្មែរក្រោមទាំងអស់បានត្រូវគេធ្វើជំរឿនពិតប្រាកដមែនទែនហើយឬនៅ ? សូម្បីតែនៅសម័យដែលបារាំងត្រួតត្រានោះក៏ដោយ ? បើទោះបីគេមិនអាចប្រកែកបានថា មានខ្មែរក្រោមខ្លះដែរបានចូលសញ្ជាតិជាយួននោះ ក៏គេមិនអាចគិតថានៅតំបន់ភូមិភាគខ្លះនៃដែនដីកូសាំងស៊ីន ដែលនៅជាខ្មែរនោះក៏មានជនជាតិយួនភាគខ្លះ មាននិន្នាការប៉ុងប្រាថ្នាចង់ចូលសញ្ជាតិជាខ្មែរដែរ ?? ។ល។

ដូច្នេះវានៅសល់តែតារាងដែលយើងលើកយកមកបង្ហាញតែប៉ុណ្ណោះ ដោយសំអាងទៅលើអំណោយផ្តល់ឲ្យដោយពិតប្រាកដ ( se fonde sur des données concrètes et traduit une certaine logique statistique ) ហើយដែលបានបង្ហាញនូវភាពសមរម្យទៅតាមស្ថិតិ ។ ទោះបីមានការកែសំរួលខ្លះៗក៏ដោយ ក៏តារាងនោះបានបង្ហាញនូវរូបភាពដ៏មធ្យម ដែលគេអាចចាត់ទុកថា ជាការវិវត្តន៍ដ៏ត្រឹមត្រូវនៃជនជាតិខ្មែរទាំងឡាយរស់នៅលើដែនដីកូសាំងស៊ីន ស្របតាមរយៈការកំណើនឡើងជាលំដាប់ ។ យើងសូមបន្ថែមជាចុងក្រោយបង្អស់ថា ការទាញពន្លាយន័យ ( les extrapolation ) នាចុងពាក់កណ្តាលសតវត្សទី២០នោះ ឥតបានគិតផងទេពីផលវិបាកនៃការកើនឡើងឬស្រកចុះរបស់ប្រជាពលរដ្ឋនៅសម័យសង្គ្រាមឥណ្ឌូចិន ( des Guerres d'Indochine ) ព្រោះការនោះមកដល់ពេលបច្ចុប្បន្ន ហាក់បីដូចគេមិនសូវយកចិត្តទុកដាក់ផងទេ ។ ការទាញពន្លាយន័យនោះឯងជាការមិនអនុញ្ញាតឲ្យគេគូសបញ្ជាក់បង្ហាញផងទេថា ក្នុងបញ្ជីដែលបានកត់ត្រា ថាមានខ្មែរ

ក្រោមទាំងអស់១លានកន្លះនៅដំណាច់ឆ្នាំ១៩៨០ ។ អង្គធាតុផ្សែផ្សំ ( la composante ) ខ្មែរក្រោម បន្ទាប់ពីមានភាពបាត់បង់ប្រជាជនមួយចំនួនក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០នៅប្រទេសកម្ពុជា បានក្លាយទៅជាថ្មីវិញ ជាកូនសោមួយក្នុងចំណោមសោដទៃទៀតសំរាប់អនាគតរបស់ប្រជាជាតិ ( La composante Khmers Krom est devenue ou redevenue une des clefs de l'Avenir de la Nation Khmère )

## តារាងដោយសង្ខេបស្ដីពីការវិវត្តន៏នៃខ្មែរក្រោម

| ឆ្នាំ | ចំនួនជាមធ្យម | អាត្រាកំណើន |
|---|---|---|
| ១៨៥៥ | ២០០,០០០នាក់ | |
| ១៨៧៥ | ២១៥,០០០នាក់ | ០.១៥% |
| ----- | | |
| ----- | | |
| ១៨៩០ | ២២០,០០០នាក់ | ០.២៥% |
| ----- | | |
| ១៩០០ | ២៣០,០០០នាក់ | ០.៣៥% |
| ១៩០៥ | ២៣៦,០០០នាក់ | ០.៥៥% |
| ១៩១០ | ២៤៤,០០០នាក់ | ០.៨០% |
| ១៩១៥ | ២៥៦,០០០នាក់ | ១.០៥% |
| ១៩២០ | ២៧២,០០០នាក់ | ១.៣០% |
| ១៩២៥ | ២៩២,០០០នាក់ | ១.៥៥% |
| ១៩៣០ | ៣១៤,០០០នាក់ | ១.៨០% |
| ១៩៣៥ | ៣៥០,០០០នាក់ | ២.០៥% |
| ១៩៤០ | ៣៩០,០០០នាក់ | ២.៣០% |
| ----- | | |
| ១៩៥០ | ៥០៤,០០០នាក់ | ២.៨០% |
| ១៩៦៥ | ៧៨៣,០០០នាក់ | ៣% |
| ១៩៨៥ | ១,៩០០,០០០នាក់ | |

ដោយ ហង្សាក់-ណោប៉ូត